ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 05-Aug-2011, 14:29
CMS/CFO: Uch Arun

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី៥ ខែសីហា ឆ្នាំ២០១១ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយ កសចស ឬ អង្គជំនុំជម្រះ: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**សំណើរបស់សហព្រះរាជអាជ្ញា ពាក់ព័ន្ធនឹងការខកខានជាលើកទីពីររបស់ នួន ជា ក្នុងការមិនបានអនុវត្តតាមដីកាសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដើម្បីផ្ដល់បញ្ជីឯកសារ និងវត្ថុតាងដែលខ្លួនមានបំណងចង់ដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

---

**អ្នកដាក់ឯកសារ:**
សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**
អង្គជំនុំជម្រះសាលាដំបូង:
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រមJean-Marc LAVERGNE
ចៅក្រម ធូ មណី

សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:
លោក ពេជ អង្គ
Elisabeth SIMONNEAU FORT

**ចម្លងជូន:**
ជនជាប់ចោទ:
នួន ជា
អៀង សារី
អៀង ធីរិទ្ធ
ខៀវ សំផន

មេធាវីការពារក្ដីជនជាប់ចោទ:
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor Koppe
លោក អាង ឧត្តម

លោក Michael G.KARNAVAS
លោក ផាត់ ពៅស៊ាង
កញ្ញា Diana ELLIS QC
លោក ស សូវាន
លោក Jacques VERGÈS

## I. សេចក្តីផ្តើម

១- នៅក្នុងសវនាការជំនុំជម្រះក្តីព្រហ្មទណ្ឌដ៏ធំដូចករណីរឿងក្តី ០០២ នេះ ជាការសំខាន់ណាស់ដែលគេត្រូវធ្វើយ៉ាងណាឱ្យការគ្រប់គ្រងរដ្ឋបាលនៃយុត្តិធម៌ឱ្យបានត្រឹមត្រូវ ដែលគូភាគីទាំងអស់ត្រូវតែគោរព និងអនុវត្តតាមដីកាសម្រេច និងវិធានរបស់តុលាការ។ នួន ជា បានបដិសេធពីរដងរួចមកហើយ មិនបានអនុវត្តតាមដីកាបង្គាប់ដើម្បីរៀបចំសវនាការ ដែលតម្រូវឱ្យគាត់កំណត់អត្តសញ្ញាណឯកសារទាំងឡាយដែលខ្លួនមានបំណងចង់ដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ ការមិនផ្តល់នូវបញ្ជីឯកសារណាមួយដូច្នេះ ជនជាប់ចោទរឹតតែបានធ្វើឱ្យមានការលំបាកកាន់តែខ្លាំងឡើង ចំពោះអង្គជំនុំជម្រះសាលាដំបូង និងភាគីដទៃទៀតដើម្បីរៀបចំសម្រាប់សវនាការ និងគំរាមកំហែងដើម្បីពន្យារពេល និងរំខានដល់ដំណើរការសវនាការជំនុំជម្រះក្តី។

២- ទន្ទឹមនេះ សហព្រះរាជអាជ្ញាសូមស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងច្រានចោលជាមុន ចំពោះមេធាវីការពារក្តី នួន ជា មិនឱ្យបង្ហាញនៅពេលសវនាការនូវឯកសារទាំងឡាយដែលមិនបានកំណត់អត្តសញ្ញាណស្របតាមដីកាបង្គាប់ដើម្បីរៀបចំសវនាការ។ ក្នុងរបៀបមួយផ្សេងពីនេះ អង្គជំនុំជម្រះសាលាដំបូងគួរបង្គាប់ឱ្យជនជាប់ចោទដាក់បញ្ជីឯកសារ និងវត្ថុតាងនៅក្នុងអំឡុងពេលពីរសប្តាហ៍ ហើយបើខកខានមិនបានអនុវត្តតាមនោះ គាត់នឹងត្រូវទទួលទណ្ឌកម្មតាមរយៈការច្រានចោលជាមុនយ៉ាងដូច្នេះ។

## II. ប្រវត្តិនីតិវិធីដែលពាក់ព័ន្ធ

៣- នៅថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានចេញដីកាបង្គាប់មួយឱ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ (“ដីកាបង្គាប់ដើម្បីរៀបចំសវនាការបឋម”)[1] ដោយបង្គាប់ឱ្យគូភាគីទាំងអស់ដាក់ “បញ្ជីឯកសារ និងវត្ថុតាង” មិនឱ្យហួសពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១១[2] ដែលកាលបរិច្ឆេទនេះ ក្រោយមកត្រូវបានពន្យារពេលរហូតដល់ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១១[3]។ នៅថ្ងៃទី១ ខែមេសា

[1] ឯកសារ E9 ដីកាបង្គាប់ឱ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ, ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១, ERN 00635754-59 [ចាប់ពីនេះតទៅហៅថា “ដីកាបង្គាប់ដើម្បីរៀបចំសវនាការបឋម”] ។

[2] *ដីកាបង្គាប់ដើម្បីរៀបចំសវនាការបឋម*, កថាខ័ណ្ឌទី១២ ។

[3] ឯកសារ E68 អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា “ការឈប់សម្រាករបស់ចៅក្រមក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីខ្មែរ”, ២៨ មីនា ២០១១, ERN 00656478 ។

ឆ្នាំ២០១១ មេធាវីការពារក្តី អៀង សារី បានដាក់សារណាមួយដែលមានចំណងជើងថា "បញ្ជីឯកសារបឋមរបស់ អៀង សារី ដែលមាននៅក្នុងសំណុំរឿងរួចហើយ និងការជូនដំណឹងពីបញ្ជីបឋមនៃឯកសារថ្មីរបស់គាត់ដែលនឹងមកដល់ ដើម្បីដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង" ("សារណាលើកទីមួយ")[4]។ សារណាលើកទីពីរ[5] និងលើកទីបី[6] ត្រូវបានដាក់ដោយ អៀង សារី នៅថ្ងៃទី៨ និង ទី១៩ ខែមេសា ឆ្នាំ២០១១ ជាបន្តបន្ទាប់រៀងៗខ្លួន។ នៅថ្ងៃទី ១៩ ខែ មេសា ឆ្នាំ២០១១ នេះដែរ មេធាវីការពារក្តី នួន ជា ក៏បានដាក់ការជូនដំណឹងមួយអំពីការចូលរួមជាមួយសារណារបស់ អៀង សារី[7]។

៤- នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១១ នៅក្នុងថ្ងៃដំបូងនៃសវនាការបឋមសម្រាប់សំណុំរឿង ០០២ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឲ្យគូភាគីកំណត់អត្តសញ្ញាណឯកសារ និងវត្ថុតាង ដែលខ្លួនគិតថាពាក់ព័ន្ធនឹងសវនាការដំណាក់កាលដំបូង មិនឲ្យហួសពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១[8]។ នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១ មេធាវីការពារក្តី នួន ជា បានដាក់សេចក្តីសង្កេតរបស់ខ្លួន ទាក់ទងនឹងឯកសារដែលខ្លួនគិតថាពាក់ព័ន្ធនឹងសវនាការដំណាក់កាលដំបូង[9]។ នៅក្នុងការដាក់ឯកសារទាំងពីរលើករបស់គាត់ គឺនៅថ្ងៃទី ១៩ មេសា ២០១១ និង ២២ កក្កដា ២០១១ នួន ជា បដិសេធមិនបង្ហាញអត្តសញ្ញាណឯកសារជាក់លាក់ណាមួយ ដែលខ្លួនមានបំណងចង់ដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[10]។

## III. **អង្គហេតុដែលពាក់ព័ន្ធ**

[4] ឯកសារ E9/22 បញ្ជីឯកសារបឋមរបស់ អៀង សារី ដែលមាននៅក្នុងសំណុំរឿងរួចហើយ និងការជូនដំណឹងពីបញ្ជីបឋមនៃឯកសារថ្មីរបស់គាត់ដែលនឹងមកដល់ ដើម្បីដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង, ១ មេសា ២០១១, ERN 00659454-69 ["បញ្ជីឯកសារទីមួយរបស់ អៀង សារី"] ។

[5] ឯកសារ E9/24 បញ្ជីឯកសារបឋមទីពីររបស់ អៀង សារី, ៨ មេសា ២០១១, ERN 00664133-36 ["បញ្ជីឯកសារទីពីររបស់ អៀង សារី"] ។

[6] ឯកសារ E9/25 បញ្ជីឯកសារបឋមទីបីរបស់ អៀង សារី, ១៩ មេសា ២០១១, ERN 00665535-37 ["បញ្ជីឯកសារទីបីរបស់ អៀង សារី"] ។

[7] ឯកសារ E9/26 ការជូនដំណឹងអំពីការចូលរួមជាមួយនឹងសារណាបឋមរបស់ អៀង សារី ទាក់ទងនឹងឯកសារដែល ត្រូវលើកយកមកសំអាង នៅសវនាការនិងសារណាបន្ថែមទាក់ទងនឹងឯកសារថ្មី, ១៩ មេសា ២០១១, ERN 00665543-46 ["ការជូនដំណឹង អំពីការចូលរួមរបស់ នួន ជា"] ។

[8] ឯកសារ E1/4.1 ប្រតិចារិកសាធារណៈ នៃសវនាការបឋម, ២៧ មិថុនា ២០១១, ERN 00712161 ។

[9] ឯកសារ E109/3 សេចក្តីសង្កេតអំពីឯកសារដែលពាក់ព័ន្ធនឹងសវនាការដំណាក់កាលដំបូង, ២២ កក្កដា ២០១១, ERN 00717666-70 ["សេចក្តីសង្កេតរបស់ នួន ជា"] ។

[10] *ការជូនដំណឹងអំពីការចូលរួមរបស់ នួន ជា*, កថាខ័ណ្ឌទី២ ។ *សេចក្តីសង្កេតរបស់ នួន ជា*, កថាខ័ណ្ឌទី១, ៤ ។

*ដីកាសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង*

៥- នៅក្នុងកថាខ័ណ្ឌទី១២ នៃដីកាសម្រេចស្ដីពីការរៀបចំសវនាការបឋម តម្រូវឲ្យភាគីនិមួយៗផ្ដល់មិនឲ្យហួសពីថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១១ នូវ៖

i) បញ្ជីឯកសារមួយដែលមាននៅក្នុងសំណុំរឿងរួចហើយ ដែលខ្លួនមានបំណងចង់ដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដោយធ្វើការកំណត់អត្តសញ្ញាណលេខយោងឯកសារ ចំណងជើងភាសារបស់វាឲ្យបានសមរម្យ និងប្រសិនបើមាន ត្រូវមានសេចក្ដីរៀបរាប់ខ្លីមួយអំពីខ្លឹមសារ និងចរិតលក្ខណៈរបស់ឯកសារទាំងនោះផង ។

ii) បញ្ជីឯកសារថ្មីមួយដែលខ្លួនមានបំណងចង់ដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដោយមានសេចក្ដីរៀបរាប់ខ្លីមួយអំពីខ្លឹមសារ និងចរិតលក្ខណៈរបស់ឯកសារទាំងនោះ ។

iii) "ដ្យាក្រាមនៃភស្តុតាងឯកសារ" មួយ ដែលមានបញ្ជាក់នូវភស្តុតាងឯកសារដែលគូភាគីនឹងពឹងផ្អែកទាក់ទិននឹងការចោទប្រកាន់ដែលមាននៅក្នុងដីកាដំណោះស្រាយ សម្រាប់កម្មវត្ថុនៃភស្តុតាងដែលពាក់ព័ន្ធនិមួយៗ[11] ។

៦- ដីកាបង្គាប់ទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវបានប្រាប់ឲ្យដឹងនៅពេលសវនាការបឋម៖

*"អង្គជំនុំជម្រះបានផ្ដល់យោបល់ពីដំបូងដល់ភាគីនានាថា ការបញ្ជាក់ត្រូវធ្វើក្នុងរយៈពេលមួយសមស្រប អំពីឯកសារដែលគិតថា ពាក់ព័ន្ធទៅនឹងសវនាការដំណាក់កាលដំបូង នឹងស្វែងរកពីពួកគេក្នុងពេលឆាប់ៗនេះ ។ អង្គជំនុំជម្រះស្នើដល់ភាគីឲ្យបញ្ជាក់ថាតើ ឯកសារ និងវត្ថុតាងមួយណាពីបញ្ជីឯកសារ និងវត្ថុតាងដំបូងរបស់ខ្លួនដែលខ្លួនគិតថា ពាក់ព័ន្ធទៅនឹងសវនាការដំណាក់កាលដំបូងមិនឲ្យហួសពីថ្ងៃសុក្រ ទី២២ ខែកក្កដា ឆ្នាំ២០១១"[12]* ។

[11] *ដីកាបង្គាប់ដើម្បីរៀបចំសវនាការបឋម,* កថាខ័ណ្ឌទី១២ ។

[12] ឯកសារ E1/4.1 ប្រតិចារិកសាធារណៈនៃសវនាការបឋម, ២៧ មិថុនា ២០១១, ERN 00712161 ។

*ចម្លើយតបរបស់ នួន ជា*

៧- ឯកសារតែមួយគត់ដែលបានដាក់ដោយមេធាវីការពារក្តី នួន ជា ជាការឆ្លើយតបទៅនឹងកថាខ័ណ្ឌទី១២ នៃដីកាបង្គាប់ដើម្បីរៀបចំសវនាការបឋមគឺការជូនដំណឹងអំពីការចូលរួមរបស់ខ្លួន។ ការដាក់ឯកសារនេះ គឺគ្រាន់តែបានអនុម័តយកតាមសារណារបស់ អៀង សារី តែប៉ុណ្ណោះ[13] និងខកខានមិនបានផ្តល់បញ្ជីជាក់លាក់ណាមួយដែលកំណត់អត្តសញ្ញាណឯកសារនានា ដែល នួន ជា មានបំណងចង់ដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនោះឡើយ។ ផ្ទុយទៅវិញ នួន ជា បានអះអាងបញ្ជាក់ពីការពឹងផ្អែកលើបញ្ជីឯកសារទាំងអស់នៅក្នុងសំណុំរឿង ដែលបានដាក់ដោយមេធាវីការពារក្តី អៀង សារី[14]។

៨- ការដាក់ឯកសាររបស់ អៀង សារី ដែលថា មេធាវីការពារក្តី នួន ជា បានចូលរួមនោះ គឺមានឧបសម្ព័ន្ធមួយ[15] ដែលមាន១,៤០០ទំព័រ បានចុះគ្រប់ឯកសារទាំងអស់ដែលមាននៅក្នុងសំណុំរឿងសម្រាប់ករណីរឿង ០០២ (“បញ្ជីឯកសារសំណុំរឿង”)[16]។ គេមិនបានបង្ហាញឱ្យឃើញពីការ ព្យាយាមក្នុងន័យសុចរិតដើម្បីកំណត់អត្តសញ្ញាណថាតើ ឯកសារណាមួយនៃឯកសារសំណុំរឿងទាំងអស់នេះ មេធាវីការពារក្តីមានបំណងចង់ដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដូចដែលបានតម្រូវដោយដីកាបង្គាប់ដើម្បីរៀបចំសវនាការបឋមនោះទេ ហើយក៏មិនបានបង្កើតឱ្យមាននូវកិច្ចខំប្រឹងប្រែងណាមួយ ដើម្បីបញ្ជាក់អំពីចំណុចនានានៃដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលឯកសារទាំងនោះមានការពាក់ព័ន្ធនោះដែរ។ (នៅខណៈដែល នួន ជា បានចូលរួមតែចំពោះបញ្ជីឯកសារទីមួយរបស់ អៀង សារី) ភាពខ្វះខាតដូចគ្នានេះក៏បានអនុវត្តផងដែរចំពោះបញ្ជីឯកសារបឋមទីពីររបស់ អៀង សារី ដែរ ដែលបានដាក់ជូនឧបសម្ព័ន្ធមួយមានចំនួន៥៦០ទំព័រ ចុះបញ្ជីគ្រប់ឯកសារទាំងអស់ដែលមាននៅក្នុងឃ្លាំងផ្ទុកឯកសាររួម[17] និងចំពោះសារណាទីបីរបស់គាត់ ដែលមានបញ្ជីមួយចុះឈ្មោះឯកសារ “ថ្មី” ចំនួន១,០៣៧ ដែលត្រូវដាក់ជូនអង្គជំនុំជម្រះសាលាដំបូង)[18]។

---

[13] *ការជូនដំណឹងអំពីការចូលរួមរបស់ នួន ជា,* កថាខ័ណ្ឌទី១ ។

[14] *ការជូនដំណឹងអំពីការចូលរួមរបស់ នួន ជា,* កថាខ័ណ្ឌទី២ ។

[15] ឯកសារ **E9/22.2** ឧបសម្ព័ន្ធ ក: បញ្ជីឯកសារសំណុំរឿង ០០២ ត្រឹមថ្ងៃទី ៣១ មីនា ២០១១, ១ មេសា ២០១១, ERN 00662336-663725 ។

[16] *បញ្ជីឯកសារទីមួយរបស់ អៀង សារី,* ទំព័រទី១ និង កថាខ័ណ្ឌទី១៣ ។

[17] ឯកសារ **E9/24.2** បញ្ជីឯកសារក្នុងឃ្លាំងផ្ទុកឯកសាររួម, ៨ មេសា ២០១១, ERN 00664706- 665265 ។

[18] ឯកសារ **E9/25.2** ឧបសម្ព័ន្ធ: បញ្ជីឯកសារ និងវត្ថុតាង - អៀង សារី, ១៩ មេសា ២០១១, ERN 00665582- 681 ។

៩- បន្ទាប់ពីមានការបង្គាប់បន្ថែមផ្ដល់ដោយ អង្គជំនុំជម្រះសាលាដំបូងនៅពេលសវនាការបឋមថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១១ មេធាវីការពារក្ដី នួន ជា បានបដិសេធជាថ្មីម្ដងទៀតមិនអនុវត្តតាមការបង្គាប់របស់អង្គជំនុំជម្រះទេ ហើយមិនបានកំណត់អត្តសញ្ញាណឯកសារនានាដែលខ្លួនមានបំណងចង់ដាក់នៅចំពោះមុខអង្គជំនុំជម្រះដែលពាក់ព័ន្ធនឹងវគ្គដំបូងនៃសវនាការដែរ។ ការអនុវត្តតាមការបង្គាប់របស់តុលាការ គឺជាឆន្ទៈ ហើយមិនអាចអភ័យទោសបានឡើយ ដែលនិយាយថា នួន ជា "មិនយល់ស្រប" ទៅនឹងសេចក្ដីបង្គាប់របស់អង្គជំនុំជម្រះទេ[19] និងថា មេធាវីការពារក្ដីរបស់គាត់ នៅពេលនេះ "មិនតម្រូវ និងក៏មិនអាចកំណត់អត្តសញ្ញាណឯកសារជាក់លាក់ណាមួយ ដែលខ្លួនមានបំណងពឹងផ្អែកនៅពេលសវនាការបាន" និង "សូមរក្សាសិទ្ធិពឹងផ្អែកលើឯកសារណាក៏បាន - រួមទាំងឯកសារដែលមាននៅក្នុងសំណុំរឿងនៅក្នុងឃ្លាំងផ្ទុកឯកសាររួម ("SMD") ឬ នៅកន្លែងផ្សេងទៀត - នៅពេលណាក៏បាន នៅមុនពេលបិទសវនាការលើអង្គសេចក្ដី"[20]។

## IV. ច្បាប់

*សិទ្ធិអំណាចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការបង្គាប់ឱ្យដាក់បញ្ជីឯកសារ*

១០- អង្គជំនុំជម្រះសាលាដំបូងត្រូវបានផ្ដល់អំណាចយ៉ាងច្បាស់លាស់ ដើម្បីចេញដីកាបង្គាប់ដើម្បីរៀបចំសវនាការបឋម តាមវិធាន៨០(៣) នៃវិធានផ្ទៃក្នុង ដូចខាងក្រោម :

*"៣. អង្គជំនុំជម្រះសាលាដំបូង អាចបង្គាប់ឱ្យភាគីទាំងឡាយដាក់ឯកសារតាមពេលកំណត់ មុនពេលសវនាការបឋម រួមទាំងឯកសារខាងក្រោម៖*

*ក. បញ្ជីវត្ថុតាងដែលភាគីទាំងឡាយមានបំណងប្រគល់ឱ្យសម្រាប់រឿងក្ដីនោះ ដោយមានពិពណ៌នាត្រួសៗអំពីលក្ខណៈ និងខ្លឹមសារនៃវត្ថុតាងទាំងនោះ។*

*ខ. បញ្ជីឯកសារថ្មីដោយមានភ្ជាប់សេចក្ដីសង្ខេបពីខ្លឹមសារនៃឯកសារទាំងនោះ ដែលភាគីមានបំណងចង់ដាក់នៅចំពោះមុខអង្គជំនុំជម្រះ និងបញ្ជីឯកសារដែលមានស្រាប់នៅក្នុងសំណុំរឿង ដែលបានកំណត់អត្តសញ្ញាណសមស្រប...*

[19] *សេចក្ដីសង្កេតរបស់ នួន ជា,* កថាខ័ណ្ឌទី ៤ ។

[20] *សេចក្ដីសង្កេតរបស់ នួន ជា,* កថាខ័ណ្ឌទី១ ។

៤. *អង្គជំនុំជម្រះសាលាដំបូងអាចបង្គាប់ថា ការជំទាស់ណាមួយទៅនឹងការទទួលយកវត្ថុតាង ឬ ឯកសារដូចបានកំណត់អត្តសញ្ញាណដោយភាគី អនុលោមតាមវិធាននេះ ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរបន្ទាប់ពីសវនាការបឋម ដោយស្ថិតក្នុងរយៈពេលមួយដែលបានកំណត់។ រយៈពេលនេះ ត្រូវអនុញ្ញាតផ្តល់ពេលវេលាសមស្រប សម្រាប់ភាគីដើម្បីពិនិត្យបញ្ជីនេះ ដោយអនុលោមទៅតាមវិធាននេះ"។*

*ភារកិច្ចរបស់អង្គជំនុំជម្រះសាលាដំបូង និងមេធាវីការពារក្តីក្នុងការធានានិងលើកស្ទួយ ដល់ការគ្រប់គ្រងកិច្ចការរដ្ឋបាលរបស់តុលាការឲ្យបានល្អ*

១១- លក្ខខណ្ឌដែលតម្រូវឲ្យ អវតក ចាត់វិធានការណ៍ និងរៀបចំដំណើរការនីតិវិធីរបស់ខ្លួនឲ្យស្របទៅតាមគោលការណ៍ក្នុងការគ្រប់គ្រងកិច្ចការរដ្ឋបាលរបស់តុលាការឲ្យបានល្អ ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងលក្ខន្តិកៈ និងនៅក្នុងវិធានផ្ទៃក្នុងរបស់ អវតក។ លក្ខន្តិកៈបានចែង ឧទាហរណ៍ដូចជា "អង្គជំនុំជម្រះនានារបស់សាលាជំនុំជម្រះក្តីត្រូវតែធានាថា ការជំនុំជម្រះក្តីនានាត្រូវធ្វើឡើងដោយត្រឹមត្រូវយុត្តិធម៌ និងឲ្យបានឆាប់រហ័ស ហើយត្រូវដឹកនាំធ្វើឲ្យបានស្របទៅតាមនីតិវិធីជាធរមាន..."[21]។ មានការលើកឡើងយោងផ្សេងៗជាច្រើនទៅលើការគ្រប់គ្រងកិច្ចការរដ្ឋបាលរបស់តុលាការ និងទៅលើដំណើរការនីតិវិធីដោយត្រឹមត្រូវយុត្តិធម៌ និងដោយប្រសិទ្ធភាពនៅក្នុងវិធានផ្ទៃក្នុង[22]។ ការគ្រប់គ្រងកិច្ចការរដ្ឋបាលរបស់តុលាការដែលប្រកបដោយភាពត្រឹមត្រូវយុត្តិធម៌ គឺស្ថិតនៅជាបេះដូងនៃវិធានច្បាប់[23] និងជាមូលដ្ឋានគ្រឹះនៃសិទ្ធិរបស់ជនជាប់ចោទដើម្បីទទួលបាននូវការ ជំនុំជំនុំជម្រះក្តីដោយត្រឹមត្រូវយុត្តិធម៌[24]។

[21] មាត្រា៣៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អវតក។

[22] វិធានផ្ទៃក្នុង, វិធាន១២*ស្ទួន* (២), ២២(៤),៣៥ និង៨០ស្ទួន (២)។

[23] *ករណីរឿងក្តីរបស់* Bistrovic *ទល់នឹង ប្រទេស* Croatia, *តុលាការសិទ្ធិមនុស្សនៃទ្វីបអឺរ៉ុប* (ECHR ), សំណុំរឿងលេខ 25774/05, សាលក្រមចុះថ្ងៃទី៣១ ឧសភា ២០០៧, ត្រង់កថាខណ្ឌទី ៣៧។

[24] *ករណីរឿងក្តីរបស់* Delcourt *ទល់នឹង ប្រទេសបែលហ្ស៊ិក, តុលាការសិទ្ធិមនុស្សនៃទ្វីបអឺរ៉ុប* (ECHR ), សំណុំរឿងលេខ 2689/65, សាលក្រមចុះថ្ងៃទី១៧ មករា ១៩៧០, ត្រង់កថាខណ្ឌទី២៥: *"នៅក្នុងសង្គមប្រជាធិបតេយ្យណាមួយ តាមន័យនៅក្នុងអនុសញ្ញា, សិទ្ធិក្នុងការគ្រប់គ្រងកិច្ចការរដ្ឋបាលរបស់តុលាការឲ្យប្រកបដោយភាពត្រឹមត្រូវយុត្តិធម៌គឺស្ថិតនៅកន្លែងមួយដែលខ្ពស់ជាងគេបំផុត ដែលការបកស្រាយដោយមានការកំរិតណាមួយនៃមាត្រា៦ កថាខណ្ឌទី១...នឹងមិនមានការជាប់ទាក់ទងទៅនឹងគោលដៅនិងគោលបំណងនៃបញ្ញត្តិនោះឡើយ ..."* ។

១២- លក្ខខណ្ឌ ដែលតម្រូវឱ្យធានាឱ្យមានការគ្រប់គ្រងកិច្ចការរដ្ឋបាលរបស់តុលាការឱ្យបានត្រឹមត្រូវនោះ គឺមិនមែនកំរិតតែចំពោះអង្គជំនុំជម្រះសាលាដំបូងផ្ទាល់តែប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាភារកិច្ចសម្រាប់ឱ្យមេធាវីការពារក្តីគ្រប់គ្នាទាំងអស់ដែលចូលមកបង្ហាញខ្លួន នៅចំពោះមុខអង្គជំនុំជម្រះនេះផងដែរ។ វិធាន២២.៤នៃវិធានផ្ទៃក្នុងបានចែងដោយច្បាស់ៗថា៖ "នៅក្នុងការបំពេញការងាររបស់ខ្លួនមេធាវីត្រូវគោរពតាមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀង, ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ នៅក្នុងតុលាការកម្ពុជា, វិធានផ្ទៃក្នុងទាំងនេះ, សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាល ក៏ដូចជាច្បាប់ស្តីពីលក្ខន្តិកៈមេធាវីរបស់កម្ពុជា និងបទដ្ឋាននៃក្រមសីលធម៌វិជ្ជាជីវៈដែលបានទទួលស្គាល់។ ពួកគេមានកាតព្វកិច្ចក្នុងការលើកកំពស់យុត្តិធម៌ និងដំណើរការនីតិវិធីប្រកបដោយប្រសិទ្ធភាព និងត្រឹមត្រូវ"[25]។

១៣- វិធាននេះឆ្លុះបញ្ចាំងឱ្យឃើញពីបទប្បញ្ញត្តិនៃតុលាការអន្តរជាតិនានាផ្សេងទៀត។ ឧទាហរណ៍ដូចជាក្រមសីលធម៌វិជ្ជាជីវៈសំរាប់មេធាវីការពារក្តី នៅឯតុលាការឧក្រិដ្ឋកម្មអន្តរជាតិសំរាប់ប្រទេសរ៉្វាន់ដា ("ICTR")បានចែងថា"គោលបំណងទូទៅនៃក្រមសីលធម៌នេះ គឺដើម្បីចែងពីបទដ្ឋាននៃក្រមសីលធម៌ពីសំណាក់មេធាវីដែលសមស្រប សំរាប់ផលប្រយោជន៍នៃការគ្រប់គ្រងកិច្ចការរដ្ឋបាលរបស់តុលាការឱ្យបានប្រកបដោយភាពត្រឹមត្រូវនិងយុត្តិធម៌"[26]។ គោលការណ៍នេះត្រូវបានលើកឡើងចែងដដែលៗឡើងវិញក្នុងក្រមសីធម៌វិជ្ជាជីវៈសំរាប់មេធាវី នៅឯតុលាការឧក្រិដ្ឋកម្មអន្តរជាតិសំរាប់អតីតប្រទេសយូហ្គោស្លាវី ("ICTY")[27]។ ស្រដៀងគ្នានេះដែរ ក្រមសីលធម៌វិជ្ជាជីវៈនៃតុលាការពិសេសសំរាប់ប្រទេសសៀរ៉ាឡេអូន បានចែងថា "មេធាវីការពារក្តីត្រូវធ្វើសកម្មភាពប្រកបដោយ៖ (iii) សុចរិតភាពដើម្បីនឹងធានាថា រាល់សកម្មភាពទាំងឡាយរបស់ខ្លួន នឹងមិនធ្វើឱ្យខូចកេរ្តិ៍ឈ្មោះដល់ការគ្រប់គ្រងកិច្ចការរដ្ឋបាលរបស់តុលាការនោះឡើយ"[28]។

១៤- បទប្បញ្ញត្តិអន្តរជាតិទាំងនេះ ឆ្លុះបញ្ចាំងឱ្យឃើញផងដែរអំពីភារកិច្ចស្រដៀងគ្នានេះរបស់មេធាវីការពារក្តីនៅក្នុងប្រព័ន្ធជាតិរបស់ខ្លួន។ ឧទាហរណ៍ដូចជា នៅប្រទេសនូវ៉ែលហ្សេឡង់ មេធាវីទាំងឡាយ

---

[25] វិធានផ្ទៃក្នុង, វិធាន២២(៤) ។

[26] មាត្រា៣ នៃក្រមសីលធម៌វិជ្ជាជីវៈសម្រាប់មេធាវីការពារក្តី, ចុះថ្ងៃទី១៤ មីនា ២០០៨ របស់តុលាការ ICTR។

[27] មាត្រា៧ នៃក្រមសីលធម៌វិជ្ជាជីវៈសម្រាប់មេធាវីការពារក្តីដែលចូលបង្ហាញខ្លួននៅចំពោះមុខតុលាការអន្តរជាតិ, ចុះថ្ងៃទី២៩ មិថុនា ២០០៨ របស់តុលាការ ICTY។

[28] មាត្រា៥ នៃក្រមសីលធម៌វិជ្ជាជីវៈសំរាប់មេធាវីការពារក្តីដែលមានសិទ្ធិចូលរួមសវនាការនៅចំពោះមុខតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន, ចុះថ្ងៃទី១៣ ឧសភា ២០០៦ របស់តុលាការ SCSL។

ត្រូវបានតម្រូវឱ្យ “គោរពតាមឱ្យបានខ្ជាប់ខ្ជួននូវនូវវិធានច្បាប់ និងជួយបង្កលក្ខណៈងាយស្រួលដល់ការគ្រប់គ្រងកិច្ចការរដ្ឋបាលរបស់តុលាការឱ្យបានល្អ”[29]។ នៅប្រទេសបារាំង វិធានរបស់គណៈមេធាវីនៃទីក្រុងប៉ារីសបានចែងថា៖ “ដើម្បីឱ្យមេធាវីការពារក្តីអនុវត្តនូវភារកិច្ចរបស់ខ្លួនក្នុងភាពឯករាជ្យតាមដែលលក្ខខណ្ឌតម្រូវឱ្យមាន និងក្នុងលក្ខណៈមួយដែលស្របតាមភារកិច្ចរបស់ខ្លួនដែលត្រូវចូលរួម នៅក្នុងការគ្រប់គ្រងកិច្ចការរដ្ឋបាលរបស់តុលាការនោះ ការអនុវត្តនូវមុខតំណែង និងមុខងារមួយចំនួនអាចត្រូវបានហាមឃាត់”[30]។ នៅប្រទេសហូល្លង់ “ តួនាទីរបស់[មេធាវី] នៅក្នុងការគ្រប់គ្រងកិច្ចការរដ្ឋបាលរបស់តុលាការ ត្រូវបានសង្កេតមើលឃើញថាជាតួនាទីដ៏សំខាន់ជាសារវន្តមួយ.... ដែលពួកគេគោរពតែប្រើប្រាស់មុខតំណែងនេះតាមវិធីមួយដែលជាការជួយជំរុញឱ្យការគ្រប់គ្រង កិច្ចការរដ្ឋបាលរបស់តុលាការដោយត្រឹមត្រូវ បានដំណើរការជាបន្តទៅទៀត”[31]។ នៅប្រទេសអង់គ្លេស និង Wales “[មេធាវី]ម្នាក់ៗមានភារកិច្ចលើសលប់មួយចំពោះតុលាការដែលត្រូវធ្វើសកម្មភាពដោយឯករាជ្យភាពដើម្បីជាផលប្រយោជន៍ដល់យុត្តិធម៌។ មេធាវីត្រូវជួយដល់តុលាការនៅក្នុងការគ្រប់គ្រងកិច្ចការរដ្ឋបាលរបស់តុលាការ ហើយមិនត្រូវបំភាន់ឬធ្វើឱ្យតុលាការយល់ខុសទោះដោយចេតនា ឬដោយការធ្វេសប្រហែសក៏ដោយ”[32]។

*កាតព្វកិច្ចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការធានាឱ្យមានគោលការណ៍ស្តីពីសិទ្ធិស្មើភាពគ្នា (នៅចំពោះមុខតុលាការ)*

១៥- គោលការណ៍ស្តីពីសិទ្ធិស្មើភាពគ្នានៅចំពោះមុខតុលាការ គឺជាទិដ្ឋភាពស្នូលមួយនៃដំណើរការនីតិវិធីរបស់តុលាការឱ្យបានប្រកបដោយភាពត្រឹមត្រូវយុត្តិធម៌នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល។ គោលការណ៍នេះ

---

[29] ជំពូកទី២ នៃច្បាប់ស្តីពីមេធាវីការពារក្តី និងអ្នកធ្វើលិខិតផ្ទេរសិទ្ធិ (សីលធម៌របស់មេធាវី និងការរក្សាកូនក្តី) វិធានឆ្នាំ២០០៨។

[30] មាត្រា២១.២.៥.១ នៃវិធានផ្ទៃក្នុងរបស់ការិយាល័យនៃទីក្រុងប៉ារីស ចុះថ្ងៃទី១១ មិថុនា ២០១០។ ខ្លឹមសារដើមជាភាសាបារាំងមានសេចក្តីដូចតទៅនេះ៖ “ដើម្បីអនុញ្ញាតឱ្យមេធាវីអាចអនុវត្តមុខងាររបស់ខ្លួនដោយឯករាជ្យភាពតាមលក្ខខណ្ឌតម្រូវ និងក្នុងលក្ខណៈមួយដើម្បីឱ្យស្របទៅនឹងភារកិច្ចរបស់ខ្លួនក្នុងការចូលរួមនៅក្នុងការគ្រប់គ្រងកិច្ចការរដ្ឋបាលរបស់តុលាការ ការអនុវត្តនូវវិជ្ជាជីវៈមួយចំនួនត្រូវបានហាមឃាត់ចំពោះមេធាវី”។

[31] កថាខណ្ឌទី១.២, ភារកិច្ច និងមុខងាររបស់មេធាវី, អត្ថបទជាភាសាអង់គ្លេសនៃក្រមសីលធម៌របស់គណៈមេធាវីនៃប្រទេសហុល្លង់ , វិធានស្តីពីក្រមសីលធម៌សម្រាប់មេធាវី ឆ្នាំ១៩៩២។

[32] វិធាន៣០២, នៃក្រមសីលធម៌សំរាប់គណៈមេធាវីនៃប្រទេសអង់គ្លេស និង Wales, ចុះថ្ងៃទី១៨ កញ្ញា ២០០៤។

តម្រូវឱ្យជនជាប់ចោទត្រូវតែបានដាក់ឱ្យស្ថិតនៅក្រោមនីតិវិធីតែមួយ ដូចគ្នានឹងអយ្យការដែរ[33]។ គោលការណ៍នេះត្រូវបានដាក់បញ្ចូលនៅក្នុងវិធាន២១.ក នៃវិធានផ្ទៃក្នុងដែលបានចែងថា "ដំណើរការនីតិវិធីនៅក្នុង អវតក ត្រូវតែមានយុត្តិធម៌ និងត្រូវតែគោរពគោលការណ៍ចំពោះមុខហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិនៃភាគីទាំងឡាយ"។

១៦- នៅឯតុលាការ ICTY នៅក្នុងករណីរឿងក្តីរបស់ *Kupreškić* មេធាវីការពារក្តីត្រូវបានគេតម្រូវឱ្យដាក់សេចក្តីសង្ខេបនៃចម្លើយសាក្សីរបស់មេធាវី នៅមុនពេលត្រូវបង្ហាញជូននូវករណីរបស់ខ្លួន អនុលោមតាមវិធាន៧៣*ស្ទួនបី* នៃវិធានផ្ទៃក្នុងរបស់តុលាការ ICTY។ ទោះបីជាមេធាវីការពារក្តីបានផ្តល់ជូននូវសេចក្តីសង្ខេបនៃចម្លើយសាក្សីនោះហើយក៏ដោយ ក៏ចម្លើយទាំងនោះមិនបានលំអិតដូចជាចម្លើយសាក្សីរបស់ខាងអយ្យការដែរ។ហេតុនេះ អង្គជំនុំជម្រះសាលាដំបូងក៏បានបង្គាប់ឱ្យមេធាវីផ្តល់នូវចម្លើយលំអិតរបស់សាក្សីខ្លួននៅក្នុងអម្លុងពេលពីរសប្តាហ៍យ៉ាងយូរ។ ក្នុងការធ្វើដូច្នេះ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា៖

> *"លក្ខណៈដែលសង្ខេប និងខ្លីហើយច្បាស់បំផុតនៃចម្លើយសាក្សីជាច្រើនរបស់មេធាវី...បានរំលោភ []ទៅលើគោលការណ៍ស្តីពីសិទ្ធិស្មើភាពគ្នា (នៅចំពោះមុខតុលាការ) ដោយសារខាងអយ្យការបានធ្វើការប្រាស្រ័យទាក់ទងទៅមេធាវីការពារក្តី និងទៅអង្គជំនុំជម្រះសាលាដំបូងនូវចម្លើយសាក្សីរបស់អយ្យការដែលមានលក្ខណៈលំអិតជាង នៅមុនពេលត្រូវធ្វើការបង្ហាញជូនអំពីករណីរបស់ខ្លួនដែលតាមរយៈនេះជួយឱ្យមេធាវីការពារក្តីអាចមានលទ្ធភាព ដើម្បីត្រៀមលក្ខណៈក្នុងការធ្វើការសួរដេញដោលសាក្សីភាគីបដិបក្សរបស់ខាងអយ្យការ'*[34]។

*សិទ្ធិអំណាចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការកំណត់បទបញ្ញាចំពោះដំណើរការនីតិវិធីរបស់ខ្លួន*

១៧- ទាំងនៅក្នុងកិច្ចព្រមព្រៀងស្តីពីការបង្កើត អវតក ក្តី និងទាំងច្បាប់ អវតក ក្តី គឺសុទ្ធតែអនុញ្ញាតឱ្យអង្គជំនុំជម្រះសាលាដំបូងស្វែងរកការណែនាំពីនីតិវិធីអន្តរជាតិដើម្បីធានាឱ្យមានភាពស៊ីសង្វាក់គ្នានៅក្នុង

[33] *ករណីរឿងក្តីរបស់* Dombo Beheer *ទល់នឹង ប្រទេសហុល្លង់, តុលាការសិទ្ធិមនុស្សនៃទ្វីបអឺរ៉ុប* (ECHR ), សំណុំរឿងលេខ 14448/88, សាលក្រមចុះថ្ងៃទី២៧ តុលា ១៩៩៣, កថាខណ្ឌទី ២០។

[34] សេចក្តីសម្រេច *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង* *Zoran Kupreskić* *និងគូកន, សេចក្តីសម្រេច*, សំណុំរឿងលេខ IT-95-16-T, ចុះថ្ងៃទី១១ មករា ១៩៩៩។

ដំណើរការនីតិវិធីនានានៅចំពោះមុខ អវតក ជាមួយនឹងបទដ្ឋានអន្តរជាតិនានា។ ពាក្យពេចន៍នៅក្នុងមាត្រាទាំងនេះមានលក្ខណៈស្រដៀងគ្នានិងចែងថា ក្នុងកណីបើសិនជានីតិវិធីរបស់កម្ពុជា៖

> " ....*មានការខ្វះចន្លោះមិនបានចែងទាក់ទងទៅនឹងបញ្ហាដោយឡែកណាមួយ ឬបើសិនជាមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬអនុវត្តន៍នូវវិធានដែលពាក់ព័ន្ធណាមួយនៃច្បាប់កម្ពុជា ឬបើសិនជាមានបញ្ហាណាមួយស្តីពីភាពមិនស៊ីសង្វាក់គ្នានៃវិធាននោះជាមួយនឹងបទដ្ឋានអន្តរជាតិ អាចនឹងស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកំរិតអន្តរជាតិ*"[35]។

១៨- ធាតុផ្សំដ៏សំខាន់ជាសារវ័ន្តមួយនៃសិទ្ធិអំណាច ដែលមានជាប់មកជាមួយស្រាប់របស់តុលាការណាមួយក្នុងការកំណត់បទបញ្ជាទៅលើដំណើរការនីតិវិធីរបស់ខ្លួន គឺជាសិទ្ធិអំណាចក្នុងការដាក់ទណ្ឌកម្មផ្សេងៗក្នុងករណីបើមានការមិនអនុវត្តតាមសេចក្តីបង្គាប់ណាមួយរបស់តុលាការ។ ការដាក់ទណ្ឌកម្មមួយចំនួនដែលមានសក្តានុពលមានចែងនៅក្នុងវិធាន ៣៧.៣ នៃវិធានផ្ទៃក្នុង ដែលក្នុងនោះចែងថា៖

> "*បើសិនជាការអាក់ខានសវនាការ កើតឡើងដោយការបដិសេធដោយចេតនាគិតទុកជាមុនមិនធ្វើតាមការណែនាំដោយផ្ទាល់មាត់ឬជាលាយលក្ខណ៍អក្សររបស់អង្គជំនុំជម្រះ ហើយការណែនាំនោះមានអមដោយការព្រមានដាក់ទណ្ឌកម្មក្នុងករណីកំហុសឆ្គង អង្គជំនុំជម្រះដែលប្រឈមមុខនឹងបញ្ហានេះអាចបង្គាប់ហាមឃាត់មិនឱ្យជននោះចូលរួមក្នុងកិច្ចដំណើរការនីតិវិធី តែក្នុងអំឡុងពេលនោះ បើយល់ឃើញថាសមស្រប។ ប្រសិនបើការរំខាននេះមានលក្ខណៈធ្ងន់ធ្ងរ អង្គជំនុំជម្រះអាចចាត់វិធានការណ៍សមស្រប ដូចមានចែងនៅក្នុងអនុវិធាន៥ នៃវិធាននេះ* "។

១៩- ការដាក់ទណ្ឌកម្មក៏មានចែងផងដែរ នៅក្នុងវិធានស្តីពីនីតិវិធីនិងភ័ស្តុតាង និងនៅក្នុងយុត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិនានា។ ទាក់ទងនឹងរឿងនេះ សហព្រះរាជអាជ្ញាធ្លាប់បានលើកឡើងហើយកាលពីមុនអំពីសិទ្ធិអំណាចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការអនុវត្តការដាក់ទណ្ឌកម្មផ្សេងៗទាក់ទងទៅនឹងការយល់ព្រមទទួលយកសាក្សីនានា[36] ដោយលើកសំអាងទៅលើករណីរឿក្តីរបស់ *Milan*

---

[35] មាត្រា១២ នៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល និងអង្គការសហប្រជាជាតិទាក់ទងនឹងការកាត់ក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។ មាត្រា៣៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អវតក។

[36] ឯកសារលេខ E9/15/1, ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងញត្តិស្នើសុំរបស់ អៀង សារី ដែលគាំទ្រចំពោះសាក្សីមួយចំនួនដែលបានស្នើសុំដោយក្រុមមេធាវីការពារក្តីផ្សេងៗទៀត ចុះថ្ងៃទី២៨ មីនា ២០១១, កថាខណ្ឌទី៧-៩។

*Lukic* នៅតុលាការ ICTY[37] ដែលទាក់ទងអំពីកាតព្វកិច្ចរបស់ភាគីនានា ក្នុងការដាក់បញ្ជីរាយឈ្មោះសាក្សីនិងឯកសារផ្សេងៗសំរាប់ពេលសវនាការ អនុលោមតាមវិធាន៦៥*ស្ទួនបី* របស់តុលាការ ICTY[38]។ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានបញ្ជាក់ច្បាស់អំពីសារៈសំខាន់ដែលភាគីទាំងឡាយត្រូវតែបំពេញឲ្យបានទៅតាមពេលវេលាកំណត់ និងអំពីភាពចាំបាច់ក្នុងការដាក់ទណ្ឌកម្មផ្សេងៗ បើសិនជាភាគីទាំងឡាយមិនបំពេញតាមកាតព្វកិច្ចរបស់ខ្លួនបានត្រឹមត្រូវ ដោយសំរេចថា៖

> "ជាគោលការណ៍នោះគឺ ភាគីនីមួយៗត្រូវសំរេចចិត្តថា តើសាក្សីណាខ្លះដែលត្រូវធ្វើការកោះហៅឲ្យមកផ្តល់សក្ខីកម្មរបស់ខ្លួន ភាគីនានាស្ថិតនៅក្រោមកាតព្វកិច្ចទូទៅមួយ គឺត្រូវតែបំពេញឲ្យបានទាន់តាមកាលបរិច្ឆេទកំណត់ ហើយត្រូវធ្វើសកម្មភាពដោយខិតខំយកចិត្តទុកដាក់ឲ្យបានត្រឹមត្រូវក្នុងការត្រៀមរៀបចំរបស់ខ្លួន។ អង្គជំនុំជម្រះសាលាដំបូងបានកត់សំគាល់ថា អនុលោមតាមវិធាន៦៥*ស្ទួនបី* ឍ" បានចែងថា នីតិវិធីដែលបានចែងនៅក្នុងវិធាននេះត្រូវបានអនុវត្តតាមរួចហើយៗ អង្គជំនុំជម្រះអាចដាក់ទណ្ឌកម្មចំពោះភាគីទាំងឡាយណាដែលមិនបានបំពេញទៅតាមកាតព្វកិច្ចរបស់ខ្លួន អនុលោមតាមវិធាន៦៥*ស្ទួនបី*"[39]។

២០- គោលការណ៍នេះក៏ត្រូវបានបង្ហាញឲ្យឃើញផងដែរនៅក្នុងករណីរឿងក្តីរបស់ *Kupreškić*[40] ដែលក្នុងនេះមេធាវីការពារក្តីបានបញ្ជាក់ថា ពួកគេបានមានបំណងចង់ឲ្យមេធាវីផ្តល់សក្ខីកម្មទាក់ទងនឹងអញ្ញត្រតា ប៉ុន្តែបានខកខានក្នុងការដាក់សេចក្តីជូនដំណឹងជូនតុលាការតាមដែលលក្ខខណ្ឌតម្រូវឲ្យមាន។ អង្គជំនុំជម្រះសាលាដំបូងបានសំរេចថា ក្នុងករណីបើមានការខកខានក្នុងការដាក់សេចក្តីជូនដំណឹងនៅមុនពេលសវនាការ នៅពេលដែលចុងចោទត្រូវបានទទួលសិទ្ធិឲ្យធ្វើសក្ខីកម្មដោយខ្លួនឯងនោះ "ភ័ស្តុតាងរបស់សាក្សីផ្សេងៗទៀតទាក់ទងនឹងអញ្ញត្រតា គឺនឹងត្រូវបានដកចេញដោយអង្គជំនុំ

---

[37] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង* Milan Lukic and Sredoje Lukic, សេចក្តីសម្រេចលើញត្តិរបស់អយ្យការដែលស្នើសុំឲ្យធ្វើវិសោធនកម្មវិធាន៦៥*ស្ទួន* ទាក់ទងនឹងបញ្ជីឈ្មោះសាក្សី និងស្តីពីដីកាសន្និដ្ឋាននានាដែលពាក់ព័ន្ធ, សំណុំរឿងលេខ IT-98-32/1-PT, ចុះថ្ងៃទី២២ មេសា ២០០៨, កថាខណ្ឌទី៩។

[38] វិធាន៦៥*ស្ទួន(* ឍ) របស់តុលាការ ICTY ចែងថា៖ "អង្គជំនុំជម្រះសាលាដំបូងត្រូវធ្វើការសំរេច បើសិនជាមានករណីកើតឡើង ស្តីពីទណ្ឌកម្មដែលត្រូវដាក់ទៅលើភាគីណាមួយដែលខកខានមិនបានអនុវត្តនូវកាតព្វកិច្ចរបស់ខ្លួន អនុលោមតាមវិធានបច្ចុប្បន្ននេះ។ ការដាក់ទណ្ឌកម្មនេះអាចរួមបញ្ចូលនូវការដកចេញនូវភស្តុតាងជាសក្ខីកម្មឬភស្តុតាងជាឯកសារ"។

[39] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង* Milan Lukic and Sredoje Lukic, , កថាខណ្ឌទី១៥។

[40] សេចក្តីសម្រេច*ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង* Kupreskić , សេចក្តីសម្រេច, សំណុំរឿងលេខ IT-95-16, ចុះថ្ងៃ១១ មករា ១៩៩៩។

ជម្រះសាលាដំបូង"[41]។ ការដាក់ទណ្ឌកម្មនេះមិនបានចែងដោយច្បាស់ៗ នៅក្នុងវិធានដែលពាក់ព័ន្ធឡើយ ផ្ទុយទៅវិញនោះគឺគ្រាន់តែបានចែងថា ការខកខានក្នុងការអនុវត្តតាមនោះមិនបានកំរិតសិទ្ធិរបស់ជនជាប់ចោទមិនឲ្យផ្តល់សក្ខីកម្មទាក់ទងនឹងអញ្ញត្រតានោះទេ"[42]។

*ការដាក់ទណ្ឌកម្មជាបុគ្គល*

២១- នៅក្នុងករណីលើកលែងនានា អង្គជំនុំជម្រះសាលាដំបូងមានសិទ្ធិនៅក្នុងការដាក់ទណ្ឌកម្មជាបុគ្គលក្នុងករណីដែលមានការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលតុលាការ គឺថានៅពេលមានការផ្តួចផ្តើមប្រមាថលើដំណើរការនីតិវិធី[43]។ អំណាចនេះបានចែងយ៉ាងជាក់ច្បាស់នៅក្នុងវិធាន ៣៥ ដល់ ៣៨ នៃវិធានផ្ទៃក្នុង ។ វិធាន ៣៥.១ ចែងថា៖

> *"អង្គជំនុំជម្រះវិសាមញ្ញអាចដាក់ទណ្ឌកម្ម ឬបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ចនូវជនណាម្នាក់ដែលជ្រៀតជ្រែក ដោយចេតនាពិតប្រាកដ ក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ រួមទាំងបុគ្គលដែលមានចែងដូចខាងក្រោម៖*
>
> *...*
>
> *ខ. ដោយគ្មានមូលហេតុសមស្រប បុគ្គលដែលមិនគោរពតាមសេចក្តីបង្គាប់ឲ្យចូលរួមនៅក្នុងការ ជម្រះក្តី ឬ មិនផ្តល់ឯកសារ ឬ ភស្តុតាងផ្សេងទៀតឲ្យសហចៅក្រមស៊ើបអង្កេត ឬ អង្គ ជំនុំជម្រះ" ...* ។

ពាក្យពេចន៍នៃបញ្ញត្តិនេះគឺស្ទើរតែដូចគ្នាបេះបិទទៅនឹងវាក្យស័ព្ទនៅក្នុងបញ្ញត្តិនៃតុលាការ ICTY, ICTR, SCSL និង STL[44] ។ តុលាការ ICTY បានកំណត់ថាប្រយោគ "រួមទាំងបុគ្គលដែល មានចែងដូចខាងក្រោម" មានអានុភាពជាការផ្តល់បញ្ជីមួយស្តីពីការប្រព្រឹត្តដែលមិនចេះអស់ទាំងឡាយ

---

[41] សេចក្តីសម្រេច *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង* Kupreskić , សេចក្តីសម្រេច, សំណុំរឿងលេខ IT-95-16, ចុះថ្ងៃទី១១ មករា ១៩៩៩, ទំព័រ៣។

[42] វិធាន៦៧(ខ), វិធានស្តីពីនីតិវិធី និងភស្តុតាងរបស់ តុលាការ ICTY។

[43] *រដ្ឋអាជ្ញា ទល់នឹង Delalić,* "សេចក្តីសម្រេចរបស់ប្រធានលើញត្តិរបស់រដ្ឋអាជ្ញាស្តីពីការបង្កើតកំណត់សម្គាល់ដើម្បីធ្វើការប្តូរគ្នារវាង Zejnil Delalić និង Zdravko Mucić", សំណុំរឿងលេខ IT-96-21-T, ថ្ងៃទី១១ វិច្ឆិកា ១៩៩៦, កថាខណ្ឌទី ៣៣ ។

[44] មាត្រា ៧៧.ក, វិធានស្តីពីភស្តុតាង និងនីតិវិធីសម្រាប់តុលាការ ICTY ។ មាត្រា ៧៧.ក, វិធានស្តីពីភស្តុតាង និងនីតិវិធីសម្រាប់តុលាការ ICTR ។ មាត្រា ៧៧.ក, វិធានស្តីពីភស្តុតាង និងនីតិវិធីសម្រាប់តុលាការ SCSL ។ វិធាន ៦០*ស្ទួន*, វិធានស្តីពីភស្តុតាង និងនីតិវិធីសម្រាប់តុលាការ STL ។

ដែលអាចដាក់ទណ្ឌកម្មបាន[45]។ លើសពីនេះទៀត វិធាន ៣៨.១ នៃវិធានផ្ទៃក្នុង បានអនុញ្ញាតឱ្យអង្គជំនុំជម្រះសាលាដំបូង ក្រោយពេលព្រមាន អាចដាក់ទណ្ឌកម្មចំពោះមេធាវីណាមួយ ប្រសិនបើយល់ឃើញថា ការប្រព្រឹត្តរបស់មេធាវីរូបនោះ, *ដែលលើសពីអ្វីៗទាំងអស់,* នាំឱ្យមានការរំលោភទៅលើនីតិវិធី ឬ រាំងស្ទះដល់កិច្ចដំណើរការនីតិវិធី[46]។

## V. អំណះអំណាង

២២- មេធាវីការពារក្តីរបស់ នួន ជា បានដឹង និងមានចេតនាបដិសេធមិនព្រមធ្វើតាមដីកាបង្គាប់ចំនួនពីររបស់អង្គជំនុំជម្រះសាលាដំបូង ដែលបានបង្គាប់ឱ្យភាគីនានាកំណត់អត្តសញ្ញាណលើឯកសារទាំងឡាយដែលពួកខ្លួនមានបំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។

២៣- ដូចដែលយុត្តិកម្មដែលបានអះអាង នៅក្នុងការបដិសេធមិនព្រមធ្វើតាមដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូងដូច្នោះ នួន ជា បានទទូចលើកឡើងនូវអំណះអំណាងនានាដូចខាងក្រោមនេះ៖

(១) *នៅមិនច្បាស់នៅឡើយ "ថាតើ [មេធាវីការពារក្តី] នៅតែហាមឃាត់មិនឱ្យធ្វើការស៊ើបអង្កេតនៅមុនពេលសវនាការលើអង្គសេចក្តី ក្នុងនាម [ជនជាប់ចោទ]*[47] ។

(២) *ចំនួនសាក្សីទាំងអស់ដែលត្រូវស្តាប់ចម្លើយ និងចំនួន "ដំណាក់កាល" ទាំងអស់របស់សវនាការ មិនទាន់ត្រូវបានឱ្យដឹងនៅឡើយទេ*[48] ។

(៣) *ចំនួនដ៏ច្រើន និងភាពស្មុគស្មាញ ពិបាកយល់នៃសំណុំរឿង (និង SMD) ធ្វើឱ្យមានការលំបាក និងចំណាយពេលច្រើនក្នុងការកំណត់ឯកសារពាក់ព័ន្ធ និងបង្ហាញទៅជនជាប់ចោទឱ្យដឹង និងមានការឆ្លើយតបពីគាត់វិញ*[49] ។ *ហើយនិង*

---

[45] *នៅក្នុងករណីប្រឆាំងនឹង* Florence Hartman, "សាលក្រមស្តីពីការលើកឡើងចោទប្រកាន់ពីការប្រមាថ", ថ្ងៃទី១៤ កញ្ញា ២០០៩, សំណុំរឿងលេខ IT-02-54-R77.5, កថាខណ្ឌទី ១៩ ។

[46] វិធាន ៣៨.១ នៃវិធានផ្ទៃក្នុង ។

[47] ការកត់សម្គាល់របស់ នួន ជា, កថាខណ្ឌទី ២.ក ។

[48] ការកត់សម្គាល់របស់ នួន ជា, កថាខណ្ឌទី ២.ខ ។

*(៤) ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាមិនបានតម្រូវឱ្យមានការជូនដំណឹងជាមុន ទាក់ទងនឹងសិទ្ធិបញ្ជាក់ភ័ស្តុតាងក្នុងពេលសវនាការ[50] ។*

២៤- មូលហេតុដែលបានអះអាងទីមួយ ដែលមេធាវីការពារក្តី នួន ជា បានដាក់បង្ហាញថា គាត់មិនដឹងទេថាតើគេអនុញ្ញាតឱ្យធ្វើការស៊ើបអង្កេត និងប្រមូលឯកសារថ្មីៗក្នុងនាមជនជាប់ចោទដែរ ឬមួយ យ៉ាងណានោះ គឺមិនបានធ្វើយុត្តិកម្មទៅលើការបដិសេធមិនព្រមធ្វើការកំណត់អត្តសញ្ញាណឯកសារទាំងឡាយដែលបច្ចុប្បន្ននេះពួកគាត់បានដឹងរួចមកហើយនោះទេ។ ពាក់ព័ន្ធនឹងបញ្ហានេះ អយ្យការ និងភាគីដទៃទៀត គឺស្ថិតនៅក្នុងស្ថានភាពដូចជា នួន ជា ដែរ។ ភាគីណាក៏ដោយ ដែលនៅពេលបន្តបន្ទាប់មកទៀត បានរកឃើញឯកសារពាក់ព័ន្ធថ្មីៗ និងមានមូលហេតុល្អៗ គឺអាចដាក់ភ័ស្តុតាងនោះជូនទៅអង្គជំនុំជម្រះសាលាដំបូងបាន ដោយអនុលោមតាមវិធាន ៨៧.៤ នៃវិធានផ្ទៃក្នុង។

២៥- ស្រដៀងគ្នានេះដែរ អង្គហេតុពិតដែលថាមេធាវីការពារក្តី នួន ជា នៅមិនទាន់បានដឹងពីអត្តសញ្ញាណរបស់សាក្សីទាំងអស់ដែលនឹងត្រូវបានស្តាប់ចម្លើយនៅពេលសវនាការ ឬរបៀបជាក់លាក់ដែលអង្គជំនុំជម្រះសាលាដំបូងនឹងត្រូវរៀបចំធ្វើសវនាការបន្ទាប់ពីដំណាក់ការដំបូងទាំងបួននោះ គឺមិនបានធ្វើយុត្តិកម្មទៅលើការបដិសេធរបស់ពួកគាត់ ក្នុងការផ្តល់បញ្ជីឯកសារសម្រាប់សវនាការនៅពេលនេះទេ។ ដូចជាភាគីទាំងអស់ដូច្នោះដែរ នួន ជា បានដឹងពីការលើកឡើងចោទប្រកាន់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងបានដឹងពីឯកសារនានាដែលមាននៅក្នុងសំណុំរឿង ឬដែលអាចរកបាននៅក្នុង SMD ហើយក៏គ្មានមូលហេតុអ្វីបដិសេធមិនព្រមធ្វើការកំណត់អត្តសញ្ញាណលើឯកសារទាំងនោះដែរ ដែលបច្ចុប្បន្ននេះគាត់យល់ឃើញថាមានការពាក់ព័ន្ធទៅនឹងការការពារក្តីរបស់គាត់ និងមានបំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។

២៦- មូលហេតុទីបីដែលមេធាវីការពារក្តីរបស់ នួន ជា បានផ្តល់ឱ្យ គឺថាទំហំនៃសំណុំរឿង និង SMD បានធ្វើឱ្យ "មានការលំបាក និងចំណាយពេលច្រើន" ក្នុងការកំណត់អត្តសញ្ញាណលើឯកសារពាក់ព័ន្ធ។ យ៉ាងណាក៏ដោយ ជនជាប់ចោទមិនធ្លាប់បានស្នើសុំពន្យារពេលកំណត់ដើម្បីធ្វើការកំណត់សញ្ញាណ

[49] ការកត់សម្គាល់របស់ នួន ជា, កថាខណ្ឌទី ២.គ ។

[50] ការកត់សម្គាល់របស់ នួន ជា, កថាខណ្ឌទី ២.ឃ ។

លើឯកសារពាក់ព័ន្ធទៅនឹងដំណាក់កាលទាំងបួនដំបូងនៃសវនាការទេ។ ផ្ទុយទៅវិញ មេធាវីការពារក្តី គ្រាន់តែបាន "មិនយល់ព្រម" ធ្វើតាមដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូងប៉ុណ្ណោះ ហើយបាន ប្រកាសថាខ្លួននឹង "បង្ហាញក្នុងពេលសមស្របនូវឯកសារទាំងអស់ដែលខ្លួននឹងប្រើនៅចំពោះមុខអង្គ ជំនុំជម្រះ"[51]។ និយាយម្យ៉ាងទៀត មេធាវីការពារក្តីរបស់ នួន ជា បានសន្មតជាមុនក្នុងការប្រគល់នូវ សិទ្ធិ និងអំណាចនានារបស់អង្គជំនុំជម្រះនេះឲ្យដល់ខ្លួនឯង និងបានអនុញ្ញាតឲ្យខ្លួនឯងមានការពន្យារ ពេលមួយដែលចំហរ និងមិនមានកំណត់ក្នុងការកំណត់អត្តសញ្ញាណលើឯកសារនានាសម្រាប់ សវនាការ។

២៧- ការប្រព្រឹត្តិរបស់មេធាវីការពារក្តី នួន ជា នៅក្នុងបញ្ហានេះមិនអាចអត់ឱនឲ្យបានទេ។ អយ្យការ និង ភាគីនានាបានប្រឈមនឹងការលំបាក និងកិច្ចការដែលប្រើពេលវេលាច្រើន ដូចគ្នានឹង នួន ជា ដែរ។ នៅក្នុងការដាក់បញ្ជីឯកសារសម្រាប់សវនាការដំបូងរបស់ខ្លួនកាលពីថ្ងៃទី១៩ ខែមេសាឆ្នាំ២០១១ និង ការកំណត់អត្តសញ្ញាណលើឯកសារនានា ដែលយល់ឃើញថាមានការពាក់ព័ន្ធទៅនឹងដំណាក់កាលមុន គេនៃសវនាការកាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាបានប្រឹង ប្រែងធ្វើឡើងដោយ សុចរិតបំផុត ដើម្បីកំណត់អត្តសញ្ញាណលើឯកសារពាក់ព័ន្ធនានាសម្រាប់ សវនាការពីក្នុងសំណុំរឿង និងពីប្រភពនានាដទៃទៀតដែលអាចរកបាន តាមកាលបរិច្ឆេទដែលអង្គជំនុំជម្រះសាលាដំបូងបាន កំណត់។

២៨- មេធាវីការពារក្តីរបស់ នួន ជា ខកខានមិនបានប្រឹងប្រែងធ្វើដូច្នោះដោយសុចរិតទេ ដូច្នេះពេលនេះ ត្រូវតែប្រឈមនឹងផលវិបាកនៃការបដិសេធមិនព្រមធ្វើតាមដីកាបង្គាប់របស់អង្គជំនុំជម្រះ។ វាជាការ មួយមិនគ្រប់គ្រាន់ទេ សម្រាប់ភាគីមួយដែលគ្រាន់តែដាក់បញ្ចូលនូវសំណុំរឿងទាំងស្រុង ដែល មាន ជាង១៨.០០០ឯកសារ ហើយនិង SMD ថាជាបញ្ជីឯកសារសម្រាប់សវនាការរបស់ខ្លួន។ គេមិនយល់ ឃើញថាអំពើបែបដូច្នេះ ជាការធ្វើឡើងដោយសុចរិតតាមដីកាបង្គាប់ត្រៀមរៀបចំសវនាការរបស់ អង្គជំនុំជម្រះនោះទេ បើមានការខូចអត្ថប្រយោជន៍ដល់អង្គជំនុំជម្រះសាលាដំបូង សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការដែលពួកគេមានលទ្ធភាពដើម្បីត្រៀមរៀបចំសម្រាប់សវនាការ

[51] ការកត់សម្គាល់របស់ នួន ជា, កថាខណ្ឌទី ១, ៤ ។

ហើយកាន់តែមានការលំបាកច្រើនឡើងថែមទៀតចំពោះអង្គជំនុំជម្រះ ក្នុងការធានាឲ្យមានសវនាការមួយដែលត្រឹមត្រូវ និងឆាប់រហ័សសម្រាប់គ្រប់ភាគីទាំងអស់[52]។

២៩- បណ្តឹងពីមុនដែលថាគ្មានពេលគ្រប់គ្រាន់ដោយក្រុមមេធាវីការពារក្តី ដើម្បីត្រៀមរៀបចំបង្ហាញ និងដាក់ឯកសារដោយអនុលោមតាមវិធាន៨០របស់ពួកគេ ត្រូវបានច្រានចោលដោយអង្គជំនុំជម្រះសាលាដំបូង។ នៅក្នុងសេចក្តីសម្រេចនានាដែលបានចេញជាង៥ខែកន្លងមកហើយ នៅថ្ងៃទី១៤ និងថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១១ អង្គជំនុំជម្រះបានច្រានចោល ការស្នើសុំពន្យារពេលដាក់ឯកសារទាំងនេះ របស់ក្រុមមេធាវីការពារក្តី ខៀវ សំផន និង អៀង សារី[53]។ នៅក្នុងសេចក្តីសម្រេចមួយខាងក្រោយ អង្គជំនុំជម្រះសម្រេចថា "ក្រុមមេធាវីការពារក្តី អៀង សារី បានទទួលដំណឹងអំពីកាល បរិច្ឆេទ កំណត់ពាក់ព័ន្ធ ដែលអង្គជំនុំជម្រះបានបង្គាប់ចាប់តាំងពីបាន ចេញដីកាបង្គាប់ឲ្យដាក់ សម្ភារៈ (ឯកសារE9) ដែលអាចរកបាននៅក្នុងសំណុំរឿង ព្រមទាំងព័ត៌មានពាក់ព័ន្ធភាគច្រើនតាំងតែពីចាប់ ផ្តើមកិច្ចស៊ើបសួរ ហេតុដូច្នេះហើយមិនអាចទាមទារថា គ្មានពេលវេលាគ្រប់គ្រាន់សម្រាប់រៀបចំការ ជំទាស់របស់ខ្លួនទេ"[54]។ ក្រុមមេធាវីការពារក្តី នួន ជា អាចស្វែងរកឯកសារបានស្រដៀងគ្នានេះដែរ នៅក្នុងសំណុំរឿងដែលកំពុងតែបន្ត ដែលរហូតមកដល់ពេលនេះ មានរយៈពេលជិតបួនឆ្នាំមកហើយ ហើយមិនមានមូលហេតុសមស្របដើម្បីទាមទារដែលថា ពួកគេគ្មានពេលវេលាគ្រប់គ្រាន់ ក្នុងការរៀបចំឯកសារ និងបញ្ជីភ័ស្តុតាងទេ។

៣០- យុត្តិកម្មទីបួន និងចុងក្រោយដែលមេធាវីការពារក្តីរបស់ នួន ជា បានលើកឡើងចំពោះការមិនព្រមធ្វើតាមរបស់ខ្លួននោះ គឺអំណះអំណាងដែលថាច្បាប់កម្ពុជាមិនបានតម្រូវឲ្យមានជាបញ្ជីឯកសារសម្រាប់សវនាការទេ។ សហព្រះរាជអាជ្ញាសូមជូនសេចក្តីសន្និដ្ឋានថា អំណះអំណាងបែបដូច្នោះ គឺគ្មានមូលដ្ឋានត្រឹមត្រូវនោះទេ ព្រោះថាវិធានផ្ទៃក្នុងសម្រាប់ អ.វ.ត.ក អនុញ្ញាតឲ្យអង្គជំនុំជម្រះ ធ្វើ

---

[52] មាត្រា ១៤.១ និង ១៤.២, កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, ឆ្នាំ១៩៦៦, ៩៩៩ UNTS ១៧១ ។

[53] ឯកសារលេខ E9/6/1 ការជូនដំណឹងអំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំពន្យាពេលដាក់ឯកសារ ភ័ស្តុតាង (E9/6) ចុះថ្ងៃទី១៤ កុម្ភៈ ឆ្នាំ២០១១, លេខ ERN 00644104។ ឯកសារលេខ E9/7/1សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំពន្យាពេលដាក់ការជំទាស់ទៅលើសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ(E9/7 និង E9/4/9) ចុះថ្ងៃទី២៨ កុម្ភៈ ឆ្នាំ២០១១, លេខ ERN 00648637។

[54] ឯកសារលេខ E9/7/1សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំពន្យាពេលដាក់ការជំទាស់ទៅលើសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ(E9/7 និង E9/4/9) ចុះថ្ងៃទី២៨ កុម្ភៈ ឆ្នាំ២០១១, លេខ ERN 00648637។

ការស្វែងរកនូវសេចក្តីណែនាំនៅក្នុងការអនុវត្តជាអន្តរជាតិ ខណៈដែលច្បាប់កម្ពុជាមិនបានធ្វើបញ្ញត្តិពីការណ៍ជាក់លាក់ណាមួយ ដូចជានៅក្នុងករណីបច្ចុប្បន្ននេះជាដើម[55]។ ទាក់ទងទៅនឹងការអនុវត្តជាទូទៅនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិនានាដែលបានបញ្ចូលទៅក្នុងវិធាន ៨០.៣ នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងត្រូវបានអនុញ្ញាតឲ្យចេញដីកាបង្គាប់ដល់ភាគីនានាឲ្យ ផ្តល់នូវបញ្ជីឯកសារមួយសម្រាប់សវនាការ នៅមុនពេលមានសវនាការដំបូងនេះ[56]។

៣១- សហព្រះរាជអាជ្ញា សូមជូនសេចក្តីសន្និដ្ឋានបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងមានអំណាចដាក់ទណ្ឌកម្មដល់ភាគីនានាបានទៅតាមច្បាប់កម្ពុជា និងតាមច្បាប់សម្រាប់ អ.វ.ត.ក បើភាគីនោះបានជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលដ៏ត្រឹមត្រូវរបស់តុលាការ[57]។ មេធាវីការពារក្តីរបស់ នួន ជា មានចេតនាបដិសេធទៅលើដីកាបង្គាប់ចំនួនពីររបស់អង្គជំនុំជម្រះសាលាដំបូង។ ការខកខាន ដោយចេតនា និងម្តងហើយម្តងទៀតដោយមិនព្រមធ្វើតាមដីកាបង្គាប់របស់អង្គជំនុំជម្រះ សមនឹងត្រូវទទួលការដាក់ទណ្ឌកម្ម ហើយដំណោះស្រាយដ៏សមស្របបំផុតសម្រាប់ការបដិសេធរបស់ភាគីមួយក្នុងការកំណត់អត្តសញ្ញាណលើឯកសារនានា ដែលខ្លួនមានបំណងដាក់នៅពេលសវនាការ នោះគឺការច្រានចោលជាមុនមិនឲ្យភាគីនោះដាក់បង្ហាញនូវឯកសារភ័ស្តុតាងបែបដូច្នោះ នៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីសវនាការ[58]។ សេចក្តីសម្រេចបែបដូច្នេះ គឺត្រូវគ្នាទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ

---

[55] *សូមមើល* វិធាន ៨០.៣.ឃ នៃវិធានផ្ទៃក្នុង, អនុលោមតាមមាត្រា ៣៣ថ្មីនៃច្បាប់ អវតក ។ លើសពីនេះ អត្ថបទច្បាប់ត្រូវបានបកស្រាយថា "ដោយសុចរិតតាមន័យធម្មតាដែលបានផ្តល់ឲ្យទៅពាក្យនេះនៅក្នុងបរិបទ និងដោយពាក់ព័ន្ធទៅនឹងកម្មវត្ថុ និងគោលបំណងរបស់វា" ។ មាត្រា ៣១, អនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញា, ថ្ងៃទី២៣ ឧសភា ១៩៦៩, ១១៥៥ UNTS ៣៣១ ។ ពីមុនបញ្ហានេះធ្លាប់ត្រូវបានសហព្រះរាជអាជ្ញាធ្វើការពន្យល់សង្ខេបរួចហើយ។ **E51/5/3/1,** ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងអញ្ញត្រកម្មបឋមរបស់មេធាវីការពារក្តី អនុលោមតាមវិធាន ៨៩, ថ្ងៃទី២១ មីនា ២០១១, កថាខណ្ឌទី ៨២-៨៣ ។

[56] *សូមមើលជាឧទាហរណ៍,* វិធាន ៦៥*ស្ទួន៣*.ង ដល់ ឆ, វិធានស្តីពីភស្តុតាង និងនីតិវិធីសម្រាប់តុលាការ ICTY ដែលបានធ្វើវិសោធនកម្មនៅថ្ងៃទី៨ ធ្នូ ២០១០, IT/32/Rev.45 ។ វិធាន ៧៣*ស្ទួន* និង ៧៣*ស្ទួន៣,* វិធានស្តីពីភស្តុតាង និងនីតិវិធីសម្រាប់តុលាការ ICTR ដែលបានធ្វើវិសោធនកម្ម នៅថ្ងៃទី១ តុលា ២០០៩ ។ វិធាន ៦៧, ៧៣*ស្ទួន* និង ៧៣*ស្ទួន៣,* វិធានស្តីពីភស្តុតាង និងនីតិវិធីសម្រាប់តុលាការ SCSL ដែលបានធ្វើវិសោធនកម្មនៅថ្ងៃទី២៨ ឧសភា ២០១០ ។ វិធាន ១២៧-១២៨, វិធានស្តីពីភស្តុតាង និងនីតិវិធីសម្រាប់តុលាការ STL ដែលបានធ្វើការកែប្រែនៅថ្ងៃទី២៩ វិច្ឆិកា ២០១០, STL/BD/2009/01/Rev.3 (ដោយបានដាក់បញ្ចូលនូវ STL/BD/2009/01/Rev.3/Corr.1)។

[57] *សូមមើល* វិធាន ៣៥ និង ៣៨ នៃវិធានផ្ទៃក្នុង ហើយនិង ការអនុវត្តជាអន្តរជាតិដែលបានរៀបរាប់នៅខាងលើ ។

[58] អំណាចនៅក្នុងការចេញដីដីកាបង្គាប់ឲ្យដាក់ទណ្ឌកម្មទៅលើការមិនព្រមធ្វើតាម គឺជាការអនុវត្តទូទៅនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ។ *សូមមើលជាឧទាហរណ៍ រដ្ឋអាជ្ញា ទល់នឹង Milan Lukic និង Sredoje Lukic*, សេចក្តីសម្រេចលើញត្តិរបស់រដ្ឋអាជ្ញាសុំធ្វើវិសោធនកម្មវិធាន ៦៥*ស្ទួន៣* ស្តីពីបញ្ជីឈ្មោះសាក្សី និង សារណាពាក់ព័ន្ធដទៃទៀត, សំណុំរឿងលេខ IT-98-32/1-PT, ថ្ងៃទី២២ មេសា២០០៨, កថាខណ្ឌទី៩ ។ សេចក្តីសម្រេច *រដ្ឋអាជ្ញា ទល់នឹង Kupreškić*, សំណុំរឿងលេខ IT-95-16, ថ្ងៃទី១១ មករា ១៩៩៩ ។

សាលាដំបូង កាលពីថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១១ ដែលនៅក្នុងនោះគេបានសម្រេចថា ដោយសារតែមេធាវីការពារក្ដីរបស់ អៀង សារី មិនបានផ្ដល់នូវបញ្ជីឈ្មោះសាក្សីនានា ដោយអនុលោមតាមដីកាបង្គាប់ត្រៀមរៀបចំសវនាការបឋមរបស់អង្គជំនុំជម្រះសាលាដំបូង និងដោយសារកាលបរិច្ឆេទកំណត់សម្រាប់ធ្វើកិច្ចការនោះបានផុតពេលទៅហើយ ភាគីនោះមិនមានមូលដ្ឋានដែលត្រូវស្នើសុំការអនុញ្ញាតជួបសាក្សីសក្ដានុពលទាំងនោះឡើយ[59]។

## VI. ដំណោះស្រាយដែលស្វែងរក

៣២- អាស្រ័យហេតុដូច្នេះ សហព្រះរាជអាជ្ញាសូមស្នើដោយគោរពដល់អង្គជំនុំជម្រះសាលាដំបូងសូម ធ្វើការច្រានចោលជាមុនមិនឲ្យដាក់បង្ហាញសម្រាប់សវនាការនូវឯកសារទាំងឡាយណា ដែលមិនបានធ្វើការកំណត់អត្តសញ្ញាណ ដោយអនុលោមតាមដីកាបង្គាប់ត្រៀមរៀបចំសវនាការ។ ជាជម្រើសម្យ៉ាងទៀត អង្គជំនុំជម្រះសាលាដំបូងគួរតែបង្គាប់ជនជាប់ចោទឲ្យដាក់បញ្ជីឯកសារ និងភ័ស្តុតាងនានាឲ្យបានត្រឹមត្រូវនៅក្នុងរយៈពេលចំនួនពីរសប្ដាហ៍ តែបើខកខានមិនបានធ្វើដូច្នោះ គាត់គឺត្រូវស្ថិតនៅក្រោមការដាក់ទណ្ឌកម្ម ដោយការច្រានចោលជាមុនបែបដូច្នេះ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៥ ខែសីហា ឆ្នាំ២០១១ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | [signature] |

[59] **E87/3,** សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងសំណើរបស់ក្រុមមេធាវីការពារក្ដីរបស់ អៀង សារី, ថ្ងៃទី៧ មិថុនា ២០១១, លេខERN 00702805-06 ។